

## សៀវភៅណែនាំស្តីពី

# ការរក្សាសុវត្ថិភាព
# តាមប្រព័ន្ធអនឡាញ

### សម្រាប់កុមារ និងយុវជន

រក្សាសិទ្ធិដោយ៖

APLE

## សៀវភៅណែនាំស្តីពី "ការរក្សាសុវត្ថិភាពតាមប្រព័ន្ធអនឡាញ សម្រាប់កុមារ និងយុវជន"

**រក្សាសិទ្ធិដោយអង្គការសកម្មភាពដើម្បីកុមារ (APLE) ២០២១**

សៀវភៅណែនាំនេះត្រូវបានផលិតជាភាសាខ្មែរដោយអង្គការសកម្មភាពដើម្បីកុមារ
សម្រាប់ក្រុមគោលដៅជាកុមារ និងយុវជន។

ឯកសារនេះត្រូវបានអភិវឌ្ឍ និងរចនាឡើងដោយមានការគាំទ្រថវិកាពី
អង្គការភ្លែនអន្តរជាតិកម្ពុជា Plan International Cambodia
តាមរយៈគម្រោងកិច្ចការពារជំនាន់ថ្មី Protection Plus

និងត្រូវបានបោះពុម្ពផ្សព្វផ្សាយដោយមានការគាំទ្រថវិកាពីអង្គការ
ភ្លែនអន្តរជាតិកម្ពុជា Plan International Cambodia
និងអង្គការ Bread for the World

រាល់ខ្លឹមសារនានាដែលបានបង្ហាញនៅក្នុងសៀវភៅនេះ មិនបានឆ្លុះបញ្ចាំងពី
ទស្សនៈរបស់អង្គការភ្លែនអន្តរជាតិកម្ពុជា Plan International Cambodia
និងអង្គការ Bread for the World នោះទេ។

រូបភាពទាំងអស់ ត្រូវបានរក្សាសិទ្ធិដោយអង្គការសកម្មភាពដើម្បីកុមារ ហើយ
ត្រូវបានប្រើប្រាស់ក្នុងគោលបំណងដើម្បីផ្សព្វផ្សាយអប់រំប៉ុណ្ណោះ។

**អង្គការសកម្មភាពដើម្បីកុមារ (APLE)**

ការិយាល័យកណ្ដាល រាជធានីភ្នំពេញ
ទូរស័ព្ទទំនាក់ទំនង៖ **023 996 351**
អ៊ីម៉ែល៖ info@aplecambodia.org
គេហទំព័រ៖ www.aplecambodia.org

# អារម្ភកថា

អង្គការសកម្មភាពដើម្បីកុមារ (APLE) ត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០០៣ ជាអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកដែលធ្វើការយ៉ាងយកចិត្តទុកដាក់ ក្នុងកិច្ចការប្រយុទ្ធប្រឆាំងនឹងអំពើរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ជាពិសេសការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញនៅកម្ពុជា។

កម្មវិធីសំខាន់មួយក្នុងចំណោមកម្មវិធីទាំង៤របស់អង្គការសកម្មភាពដើម្បីកុមារ គឺផ្តោតលើការចូលរួមរបស់សហគមន៍ វិស័យឯកជន និងប្រព័ន្ធផ្សព្វផ្សាយ ក្នុងការបង្ការ និងទប់ស្កាត់ហានិភ័យនៃការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ជាពិសេសការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញតាមរយៈការលើកកម្ពស់ការយល់ដឹង ការផ្តល់ការអប់រំ ជំនាញ និងវិធីសាស្ត្របង្ការ ដើម្បីជានាបានថាចំណេះដឹងត្រូវបានបញ្ជ្រាបយ៉ាងទូលំទូលាយ។ អង្គការសកម្មភាពដើម្បីកុមារបាន និងកំពុងអនុវត្តសកម្មភាពរបស់ខ្លួនមួយផ្នែកធំតាមរយៈកម្មវិធីលើកកម្ពស់ការយល់ដឹង ការបណ្តុះបណ្តាលភាគីពាក់ព័ន្ធ ជាពិសេសគឺការលើកកម្ពស់ការយល់ដឹងតាមរយៈការចែកចាយសម្ភារៈអប់រំសំខាន់ៗ។

សៀវភៅនេះ ត្រូវបានផលិតជាពិសេសសម្រាប់ក្រុមគោលដៅជាកុមារ និងយុវជនក្នុងការស្វែងយល់ពីហានិភ័យ ដែលពាក់ព័ន្ធនឹងការកេងប្រវ័ញ្ចផ្លូវភេទតាមប្រព័ន្ធអនឡាញក៏ដូចជាផ្តល់ឱ្យពួកគេនូវចំណេះដឹងដែលអាចជួយរក្សាសុវត្ថិភាពពួកគេពីហានិភ័យទាំងនោះ។

យើងខ្ញុំពិតជាសង្ឃឹមយ៉ាងមុតមាំថា សៀវភៅណែនាំនេះនឹងអាចក្លាយជាឧបករណ៍ដ៏មានសារៈសំខាន់ក្នុងការរួមចំណែកកាត់បន្ថយហានិភ័យដែលអាចកើតឡើងចំពោះកុមារ ជាពិសេសធានាថាកុមារទទួលបាននូវព័ត៌មានគ្រប់ជ្រុងជ្រោយស្តីពីការរក្សាសុវត្ថិភាពតាមប្រព័ន្ធអនឡាញ។

# សេចក្តីផ្តើម

អ៊ីនធឺណិត ផ្តល់ឱ្យកុមារនូវការកម្សាន្ត ការសិក្សារៀនសូត្រ ទំនាក់ទំនងជាមួយគ្រួសារ និងមិត្តភក្តិ ការទទួលបានព័ត៌មាន ឬការលេងហ្គេមកំសាន្តជាដើម។ ទោះជាយ៉ាងនេះក្តីកុមារ និងយុវជនវ័យក្មេងក៏អាចប្រឈមទៅនឹងហានិភ័យមួយចំនួនផងដែរ។

នៅប្រទេសកម្ពុជា តាមរយៈការវិភាគស្ថានភាពដំបូងស្តីពីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ ដែលដឹកនាំដោយក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ បានបង្ហាញថា ក្នុងចំណោមកុមារ២២០នាក់ ដែលបានចូលរួមក្នុងការសិក្សាស្រាវជ្រាវ ម្នាក់ក្នុងចំណោម៦នាក់ ធ្លាប់ប្រឈមនឹងហានិភ័យដែលទាក់ទងនឹងការកេងប្រវ័ញ្ចផ្លូវភេទតាមប្រព័ន្ធអនឡាញ ហើយភាគច្រើនស្ថិតក្នុងទម្រង់នៃការលួងលោម ឬទម្រង់ផ្សេងៗនៃការកេងប្រវ័ញ្ចផ្លូវភេទពីមនុស្សពេញវ័យតាមអនឡាញ។

ដោយមើលឃើញពីបញ្ហាប្រឈម និងផលប៉ះពាល់ រាជរដ្ឋាភិបាលកម្ពុជា បានផ្តួចផ្តើមអភិវឌ្ឍគោលនយោបាយ ក្របខណ្ឌច្បាប់ និងផែនការសកម្មភាពសំខាន់ៗជាបន្តបន្ទាប់។ ជាក់ស្តែងនាពេលថ្មីៗនេះ ក្រោមការសម្របសម្រួលរបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ផែនការសកម្មភាពដើម្បីបង្ការ ទប់ស្កាត់ និងឆ្លើយតបការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញឆ្នាំ២០២១- ២០២៥ ត្រូវបានប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការនៅថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១។ មិនត្រឹមតែប៉ុណ្ណោះ សកម្មភាពលើកកម្ពស់ការយល់ដឹង យុទ្ធនាការអប់រំផ្សព្វផ្សាយនានា ក៏ត្រូវបានរៀបចំឡើងជាបន្តបន្ទាប់ដូចជា យុទ្ធនាការគិតគូរកូន ដែលត្រូវបានបង្កើតឡើងដោយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ក្រសួងអប់រំ យុវជន និងកីឡា និងដៃគូអភិវឌ្ឍផ្សេងៗទៀត ការបង្កើតកម្មវិធីសិក្សាថ្នាក់ជាតិពាក់ព័ន្ធនឹងការបង្ការ ទប់ស្កាត់អំពើកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញតាមរយៈក្រសួងអប់រំ យុវជន និងកីឡា និងគណៈកម្មាធិការជាតិ គ.ជ.ប.ជ ជាពិសេសការដឹកនាំតាក់តែងពង្រាងច្បាប់ស្តីពីកិច្ចការពារកុមារ ដែលដឹកនាំដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាជាដើម។

ដើម្បីរួមចំណែកក្នុងការលើកកម្ពស់ការយល់ដឹងលើបញ្ហានេះ អង្គការសកម្មភាពដើម្បីកុមារ បានរៀបចំតាក់តែងនូវសៀវភៅណែនាំស្តីពី "**ការរក្សាសុវត្ថិភាពតាមប្រព័ន្ធអនឡាញ**" សម្រាប់ប្អូនៗក្នុងការសិក្សាស្វែងយល់ពីហានិភ័យដែលអាចជួបប្រទះ និងទម្រង់មួយចំនួននៃការកេងប្រវ័ញ្ចផ្លូវភេទតាមប្រព័ន្ធអនឡាញ ជាពិសេសឥរិយាបទតាមអនឡាញមួយចំនួនដែលកុមារត្រូវដឹងដើម្បីរក្សាសុវត្ថិភាព ក៏ដូចជា វិធីស្វែងរកការគាំទ្រ។

# តើប្អូនៗដឹងទេថា អ្វីទៅជាហានិភ័យដែលអាចកើតឡើង នៅពេលប្រើប្រាស់អ៊ីនធឺណិត ?

កុមារ និងយុវជនចូលចិត្តប្រើប្រាស់អ៊ីនធឺណិត ដើម្បីស្រាវជ្រាវនូវប្រធានបទដែលគួរឱ្យចាប់អារម្មណ៍ទាក់ទងជាមួយមិត្តភក្តិ រៀននូវអ្វីដែលថ្មី ជជែកឬលេងហ្គេមកំសាន្តជាដើម។ ដើម្បីឱ្យអ៊ីនធឺណិត កាន់តែក្លាយជាពិភពដ៏សប្បាយរីករាយនិងមានសុវត្ថិភាព កុមារ និងយុវជនគួរយល់ដឹងបន្ថែមពីហានិភ័យមួយចំនួនផងដែរ។




## ហានិភ័យនៃមាតិកា ( Content Risks )

កុមារ និងយុវជនអាចមើលឃើញនូវមាតិកាដែលពួកគេមិនចង់ឃើញ ឬមានលក្ខណៈមិនសមរម្យ។ វាអាចជាប្រភេទវីដេអូ រូបភាព អត្ថបទ សារសម្លេងតាម អនឡាញ ដែលមានលក្ខណៈផ្លូវភេទ អាសអាភាស ឬមានលក្ខណៈហិង្សាជាដើម។



## ហានិភ័យនៃទំនាក់ទំនង ( Contact Risks )

មនុស្សមួយចំនួន ប្រើប្រាស់អ៊ីនធឺណិត ជាមធ្យោបាយក្នុងការទាក់ទងកុមារក្នុងគោលបំណងកេងប្រវ័ញ្ចផ្លូវភេទ។ កុមារ និងយុវជនអាចចូលរួមដោយមិនបានដឹងខ្លួនក្នុងការប្រាស្រ័យទាក់ទងប្រកបដោយគ្រោះថ្នាក់ជាមួយអ្នកដទៃតាមអនឡាញ ហើយពួកគេអាចត្រូវបានគេបោកបញ្ឆោតឱ្យមានទំនាក់ទំនងបែបផ្លូវភេទ។



## ហានិភ័យនៃការប្រព្រឹត្ត ( Conduct Risks )

ពេលខ្លះកុមារ និងយុវជនខ្លួនឯងអាចមានឥរិយាបទចូលរួមចំណែកបង្កើតនូវមាតិកាបែបហានិភ័យ ឬចូលរួមក្នុងទំនាក់ទំនងបែបហានិភ័យតាមអនឡាញ។ សកម្មភាពទាំងនោះអាចជាការផលិត បង្ហោះ ឬចែកចាយរូបភាពអាក្រាត ឬរូបភាពបែបផ្លូវភេទខ្លួនឯង និងអ្នកដទៃ ដោយមិនបានយល់ដឹងពីផលវិបាកដែលនឹងកើតមានឡើង។



## ហានិភ័យនៃកិច្ចសន្យា ( Contract Risks )

ហានិភ័យនៃកិច្ចសន្យា ( Contract Risks ) អាចកើតឡើងនៅពេលដែលកុមារទាញយកកម្មវិធីថ្មីៗមកប្រើប្រាស់ ចូលទៅកាន់គេហទំព័រ ឬប្រើប្រាស់ផលិតផលឬសេវាឌីជីថល ដែលតម្រូវឱ្យកុមារចុចយល់ព្រម ( Accept ) នូវលក្ខខណ្ឌនៃសេវាកម្ម ( Terms of Service/Terms and Conditions ) ដែលពេលខ្លះកុមារមិនបានយល់ ឬមិនបានអានមុនពេលសម្រេចចិត្ត។ ការតម្រូវបែបនេះ អាចឱ្យកុមារត្រូវបានកេងប្រវ័ញ្ចតាមរយៈការប្រើប្រាស់ទិន្នន័យ ឬព័ត៌មានផ្ទាល់ខ្លួន ឬបង្កជាហានិភ័យដល់ឯកជនភាពរបស់កុមារជាដើម។

# តើអ្វីទៅ ជាការកេងប្រវ័ញ្ចផ្លូវភេទតាមប្រព័ន្ធអនឡាញ ?

ក្រៅពីការយល់ដឹងអំពីហានិភ័យដែលអាចកើតឡើងតាមប្រព័ន្ធអនឡាញ ប្អូនៗក៏ត្រូវយល់ដឹងបន្ថែមពីការកេងប្រវ័ញ្ចផ្លូវភេទតាមប្រព័ន្ធអនឡាញផងដែរ។

ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ ជាការប្រើប្រាស់អ៊ីនធឺណិតដើម្បី៖



- ជាមធ្យោបាយដើម្បីទទួលបានការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ
- ជាមធ្យោបាយបណ្តាលឱ្យកុមារត្រូវបានគេកេងប្រវ័ញ្ចផ្លូវភេទ
- ជាមធ្យោបាយក្នុងការផលិត កាន់កាប់ ចែកចាយ ឬបញ្ជូននូវរូបភាព-សម្ភារៈដែលពាក់ព័ន្ធនឹងការរំលោភបំពាន ឬកេងប្រវ័ញ្ចផ្លូវភេទលើកុមារ

ទម្រង់នៃការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញរួមមាន៖

## ទម្រង់ទី១៖ ការលួងលោមកុមារតាមប្រព័ន្ធអនឡាញ

ការលួងលោមកុមារតាមប្រព័ន្ធអនឡាញ (Online Grooming) សំដៅទៅលើសកម្មភាពជនខិលខូចដែលព្យាយាមទាក់ទងកុមារតាមប្រព័ន្ធអនឡាញ ដើម្បីកសាងទំនុកចិត្តក្នុងគោលបំណងកេងប្រវ័ញ្ចផ្លូវភេទពួកគេ។ ការលួងលោមទាំងនោះរួមមានការបង្ហាញនូវសម្ភារៈអាសអាភាស ដូចជា តាមរយៈការផ្ញើនូវ មាតិកា សារ វីដេអូ ឬ រូបភាពបែបផ្លូវភេទទៅកាន់កុមារ។ វិធីទាំងនេះអាចជួយឱ្យជនល្មើសផ្លូវភេទលើកុមារអាចបន្សាំកុមារទៅនឹងរឿងរ៉ាវផ្លូវភេទ ក្នុងគោលដៅបង្កើនឱកាសឱ្យកុមារបញ្ជូនសម្ភារៈផ្លូវភេទដោយខ្លួនឯងទៅឱ្យជនល្មើស។



## ទម្រង់ទី២៖ រូបភាព-សម្ភារៈរំលោភបំពានផ្លូវភេទលើកុមារ

រូបភាព-សម្ភារៈរំលោភបំពានផ្លូវភេទលើកុមារ (CSAM) សំដៅលើសម្ភារៈដែលបង្ហាញពីកុមារក្នុងស្ថានភាពអាក្រាត ពិពណ៌នាដោយផ្តោតលើកេរភេទរបស់កុមារឬសម្ភារៈដែលពណ៌នាអំពីកុមារនៅក្នុងស្ថានភាពបែបអាសអាភាស។ សម្ភារៈទាំងនោះរួមមាន រូបភាព វីដេអូ អត្ថបទ និងសារសម្លេង ដែលមានលក្ខណៈបែបអាសអាភាសជាដើម។




## ទម្រង់ទី៣៖ ការផ្ញើសារបែបផ្លូវភេទ

ការបញ្ជូនសារបែបផ្លូវភេទ (Sexting) គឺជាសកម្មភាពនៃការផ្ញើ ឬទទួលរូបភាពបែបផ្លូវភេទដែលបង្កើតឡើងដោយខ្លួនឯងទៅឱ្យអ្នកដទៃផ្សេងទៀត។ ពេលខ្លះ ការផ្ញើឬការបញ្ជូនរូបភាពផ្លូវភេទដែលបង្កើតឡើងដោយខ្លួនឯងត្រូវបានធ្វើឡើងដោយការស្ម័គ្រចិត្ត ឬធ្វើឡើងបន្ទាប់ពីទទួលរងការគំរាមកំហែង ការដាក់សម្ពាធ ការរៀបចំឡើង និង/ឬការបង្ខិតបង្ខំពីមនុស្សម្នាក់ទៀត។



## ទម្រង់ទី៤៖ ការគំរាមបែបផ្លូវភេទលើកុមារ

ការគំរាមបែបផ្លូវភេទ (Sextortion) គឺជាទង្វើដែលជនល្មើសផ្លូវភេទលើកុមារប្រើប្រាស់សម្ភារៈរំលោភបំពានផ្លូវភេទដែលបានទទួលពីកុមារជាញឹកញាប់តាមរយៈការផ្ញើ ឬការបញ្ជូនរូបភាពផ្លូវភេទដែលបង្កើតឡើងដោយខ្លួនឯង ដើម្បីគំរាមកុមារឱ្យបញ្ជូនសម្ភារៈផ្លូវភេទបន្ថែមទៀតដល់ពួកគេ ដើម្បីជួបផ្ទាល់ក្នុងគោលបំណងផ្លូវភេទ ឬដើម្បីទទួលបាននូវផលប្រយោជន៍ផ្សេងទៀតដូចជា លុយកាក់ ឬការគ្រប់គ្រងលើកុមារជាដើម។




## ទម្រង់ទី៥៖ ការផ្សាយផ្ទាល់អំពើរំលោភបំពានផ្លូវភេទលើកុមារ

ការផ្សាយផ្ទាល់អំពើរំលោភបំពានផ្លូវភេទលើកុមារ (Live Online Child Sexual Abuse) សំដៅលើការផ្សាយផ្ទាល់នៃសកម្មភាពរំលោភបំពានផ្លូវភេទពាក់ព័ន្ធកុមារ ឬការឱ្យកុមារសំដែងបែបផ្លូវភេទនៅមុខកាម៉េរ៉ា (អាចក្នុងស្ថានភាពអាក្រាត ឬក្នុងស្ថានភាពផ្លូវភេទ) ពេលខ្លះជនល្មើសផ្លូវភេទលើកុមារអាចផ្តល់ជាប្រាក់ដល់កុមារផ្ទាល់ អ្នកសម្របសម្រួល ឬអន្តរការី ដើម្បីដោះដូរជាមួយនឹងសកម្មភាពនោះ។



# តើប្អូនៗដឹងទេ មានកម្មវិធីតាមអនឡាញណាខ្លះ ដែលកំពុងពេញនិយមសម្រាប់អ្នកប្រើប្រាស់ ?

នៅលើអ៊ីនធឺណិត មានកម្មវិធីដ៏សម្បូរបែបជាច្រើនដែលអាចឱ្យកុមារទាញយកមកប្រើប្រាស់ជាប្រយោជន៍បាន។ ទោះជាយ៉ាងនេះក្តី វាពិតជាល្អប្រសើរណាស់ ប្រសិនបើកុមារបានយល់ដឹងបន្ថែមពីហានិភ័យដែលអាចកើតមាន តាំងពីពេលចាប់ផ្តើមប្រើប្រាស់ដំបូង។ បើយោងតាមការវិភាគស្ថានភាពដំបូងស្តីពីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញដែលដឹកនាំដោយក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ក៏បានបង្ហាញថា មានហានិភ័យមួយចំនួនស្រដៀងគ្នា ត្រូវបានលើកឡើង តាមរយៈប្រភេទកម្មវិធីដែលនិយមប្រើប្រាស់ទាំងនេះផងដែរ ដែលក្នុងនោះរួមមាន៖

## ១. បណ្តាញទំនាក់ទំនងសង្គម ( Social media and communication platforms )

**កម្មវិធីបណ្តាញទំនាក់ទំនងសង្គមជាឧទាហរណ៍រួមមាន** ហ្វេសប៊ុក ( Facebook ) អ៊ីនស្តាក្រាម ( Instagram ) កម្មវិធីផ្ញើសារ ( FB Messenger ) កម្មវិធីឡាញ ( Line ) និង Skype ជាដើម។

**តើហានិភ័យអ្វីខ្លះដែលអាចកើតមានឡើង ?** ប្រវត្តិរូបផ្ទាល់ខ្លួនដែលត្រូវបានបង្ហាញលើបណ្តាញទំនាក់ទំនងសង្គម អាចមាននូវព័ត៌មានផ្ទាល់ខ្លួនជាច្រើនរបស់អ្នកប្រើប្រាស់ ដែលអាចឱ្យជនខិលខូចទាញយកជាមធ្យោបាយដើម្បីទាក់ទង។ ម្យ៉ាងវិញទៀត កុមារក៏អាចមើលឃើញនូវមាតិកាដែលមានលក្ខណៈមិនសមរម្យតាមរយៈការបង្ហោះ និងការចែករំលែកតាមប្រព័ន្ធអនឡាញ។ ពេលខ្លះជនល្មើស ក៏អាចមានឱកាសទាក់ទងជាមួយកុមារ ផ្ញើឬបញ្ជូនសារមិនសមរម្យ ឬមានលក្ខណៈបែបផ្លូវភេទ និងបង្កគ្រោះថ្នាក់ដល់កុមារផងដែរ។

## ២. វេទិកាហ្គេមអនឡាញ ( Online Gaming Communities )

**វេទិកាហ្គេមអនឡាញដែលជាឧទាហរណ៍មានដូចជា៖** Mobile Legend, Bang Bang (MLBB), Rules of survivor, AK2 Player Unknown's Battleground (PUBG), GTA 5 ជាដើម។

**តើហានិភ័យអ្វីខ្លះដែលអាចកើតមានឡើង?** ក្រៅពីបង្កប់នូវមាតិកាដែលមានលក្ខណៈហិង្សាខ្លាំង និង មាតិកាដែលមានលក្ខណៈផ្លូវភេទ មិនសមរម្យសម្រាប់កុមារ វេទិកាហ្គេមអនឡាញក៏អាចឱ្យមនុស្សមិនល្អទាក់ទងជាមួយកុមារ ប្រមូលនូវព័ត៌មានរបស់កុមារ និងធ្វើឱ្យកុមារជឿទុកចិត្ត មុនពេលបង្វែរការទាក់ទងជាមួយកុមារតាមរយៈបណ្តាញទំនាក់ទំនងសង្គមផ្សេងទៀត ឬស្នើសុំជួបកុមារដោយផ្ទាល់។

## ៣. កម្មវិធីផ្សាយផ្ទាល់ ( Live Streaming Applications )

**កម្មវិធីផ្សាយផ្ទាល់ដែលជាឧទាហរណ៍រួមមាន៖** TikTok, Bigo Live, YouTube ជាដើម។

**តើហានិភ័យអ្វីខ្លះដែលអាចកើតមានឡើង?** កម្មវិធីផ្សាយផ្ទាល់ភាគច្រើនមានជម្រើសដែលអាចឱ្យអ្នកប្រើប្រាស់អ៊ីនធឺណិតផ្សេងទៀតបញ្ចេញមតិយោបល់ និងទាក់ទងជាមួយអ្នកបង្ហោះវីដេអូ។ លទ្ធភាពនៃការបង់ប្រាក់សម្រាប់វីដេអូ ក៏អនុញ្ញាតឱ្យជនល្មើស កេងប្រវ័ញ្ចលើកុមារតាមរយៈការបញ្ចុះបញ្ចូលឱ្យកុមារសម្តែងនៅមុខកាមេរ៉ាដើម្បីបានប្រាក់។ ម្យ៉ាងវិញទៀត ដោយសារវីដេអូផ្សាយផ្ទាល់បង្ហាញពីសកម្មភាពកំពុងប្រព្រឹត្តជាក់ស្តែង និងមិនមានការពិនិត្យជាមុន កុមារអាចមើលឃើញនូវសម្ភារៈមិនសមរម្យ។

# ចំណុចសំខាន់ៗដែលកុមារត្រូវចងចាំ !

## ១ ព័ត៌មានផ្ទាល់ខ្លួន និងរូបថតអាចត្រូវបានជនខិលខូចតាមអនឡាញទាញយកជាប្រយោជន៍

ជនខិលខូចមួយចំនួន អាចប្រើព័ត៌មានផ្ទាល់ខ្លួនរបស់កុមារ ដែលពួកគេស្វែងរកបានតាមអ៊ីនធឺណិត សម្រាប់ចេតនាអាក្រក់ៗ ជនទាំងនោះ ក៏អាចស្វែងរកព័ត៌មានផ្ទាល់ខ្លួនរបស់កុមារក្នុងគោលបំណងចាប់ផ្ដើមទាក់ទងជាមួយកុមារ ធ្វើឱ្យកុមារផ្ញើរូបភាព វីដេអូ ដែលមានលក្ខណៈមិនសមរម្យ ឬអាចស្នើសុំឱ្យកុមារផ្ញើ ឬបញ្ជូននូវរូបភាព វីដេអូ ដែលមានលក្ខណៈមិនសមរម្យឱ្យពួកគេវិញក៏មានៗ ហេតុនេះពត៌មានផ្ទាល់ខ្លួនដូចជា ពាក្យសម្ងាត់ និងឈ្មោះប្រើប្រាស់ ទីតាំង ឈ្មោះសាលារៀន កន្លែងកំសាន្តជាទៀងទាត់ ឬរូបថតដែលមានលក្ខណៈស្និទ្ធស្នាល និងបង្ហាញហួសហេតុមិនគួរមាននៅលើអ៊ីនធឺណិតនោះឡើយៗ សូមចងចាំថា៖ រូបថត និងវីដេអូបែបស្និទ្ធស្នាល ឬមានលក្ខណៈផ្លូវភេទ អាចបង្កហានិភ័យខ្លាំងចំពោះកុមារ នៅពេលវាត្រូវបានចែករំលែកតាមអ៊ីនធឺណិត បើទោះបីជារូបថតនោះ ត្រូវបានលុបចោលក៏ដោយ ក៏វាអាចត្រូវបានជនខិលខូចថតចម្លង ឬរក្សាទុកក្នុងឧបករណ៍របស់គេ ហើយរូបថត និងវីដេអូនោះ នឹងមិនអាចដក ឬ លុបចេញពីអ៊ីនធឺណិតបានទាំងស្រុងនោះឡើយៗ



## ២ ទាំងកុមារា និងកុមារីអាចត្រូវបានគេកេងប្រវ័ញ្ចផ្លូវភេទតាមប្រព័ន្ធអនឡាញ

ទាំងកុមារា និងកុមារីសុទ្ធតែអាចជួបហានិភ័យនៃការកេងប្រវ័ញ្ចផ្លូវភេទដូចគ្នាដែរ។ ការមិនបានយល់ដឹងថាកុមារាក៏អាចជាជនរងគ្រោះដែរនោះ បានធ្វើឱ្យកុមារាទទួលរងនូវភាពងាយរងគ្រោះ ព្រោះថាពួកគេនឹងមិនទទួលបានជំនួយដែលពួកគេត្រូវការបានល្អប្រសើរទេ បន្ទាប់ពីទទួលរងនូវការកេងប្រវ័ញ្ច។



## ៣ ជនល្មើសផ្លូវភេទលើកុមារភាគច្រើនជាមនុស្សដែលកុមារស្គាល់

ជារឿយៗកុមារតែងត្រូវបានគេបោកបញ្ឆោត ឬលួងលោមដោយមនុស្សដែលកុមារជឿទុកចិត្ត ហើយយល់ព្រមផ្ញើរូបភាព ឬសម្ភារៈផ្លូវភេទ ដល់ជនល្មើសតាមប្រព័ន្ធអនឡាញ។



## ៤ បើទោះបីជាការកេងប្រវ័ញ្ចផ្លូវភេទលើកុមារពេលខ្លះមិនមានការជួបទាក់ទងផ្ទាល់ជាមួយជនល្មើសក៏ដោយ វានៅតែអាចបង្កផលប៉ះពាល់ធ្ងន់ធ្ងរដូចការជួបផ្ទាល់ដែរ

ទម្រង់ជាច្រើននៃការរំលោភបំពាន និងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ជាពិសេសតាមប្រព័ន្ធអនឡាញអាចកើតឡើងបានដោយមិនចាំបាច់ទាល់តែមានការជួបផ្ទាល់ ឬការប៉ះពាល់រាងកាយផ្ទាល់រវាងជនល្មើស និងកុមារនោះឡើយ។ ឧទាហរណ៍ដូចជាការថតរូបកុមារបែបផ្លូវភេទ ការចែកចាយរូបភាពទាំងនោះតាមប្រព័ន្ធអនឡាញ ឬការបង្ហាញឱ្យកុមារឃើញនូវរូបភាពបែបផ្លូវភេទជាដើម។



## ៥ កុមារត្រូវមានភាពវៃឆ្លាត នៅពេលអនឡាញ

កុមារគ្រប់វ័យសុទ្ធតែអាចប្រឈមនឹងហានិភ័យនៃការកេងប្រវ័ញ្ចផ្លូវភេទតាមប្រព័ន្ធអនឡាញ ដូចនេះកុមារត្រូវមានភាពឆ្លាតវៃនៅពេលប្រើប្រាស់អ៊ីនធឺណិត ដោយមិនត្រូវចែករំលែកនូវព័ត៌មានផ្ទាល់ខ្លួន មិនត្រូវជួបផ្ទាល់ជាមួយមនុស្សដែលស្គាល់តែតាមប្រព័ន្ធអនឡាញ មិនត្រូវទទួលសារ ឬរូបភាពពីមនុស្សដែលមិនស្គាល់ ត្រូវពិនិត្យរាល់ព័ត៌មានដើម្បីប្រាកដថាអាចជឿទុកចិត្តបាន ជាពិសេសត្រូវមានភាពក្លាហានក្នុងការជជែកពិភាក្សាជាមួយមនុស្សពេញវ័យដែលខ្លួនទុកចិត្ត ប្រសិនបើមានអ្វីមិនល្អអាចកើតឡើងចំពោះអ្នក។



# តើត្រូវធ្វើដូចម្តេច ប្រសិនបើប្អូនៗជួបនូវបញ្ហាទាំងនោះ?

## ១. កុមារអាចអនុវត្តនូវវិធាន " ទេ-ទៅ-ប្រាប់ "

កុមារអាចដោះស្រាយចំពោះស្ថានភាពដែលពួកគេមានអារម្មណ៍ថាមិនមានសុវត្ថិភាពនៅពេលពួកគេអនឡាញ ដោយអនុវត្តគោលការណ៍ទាំងបី **"ទេ ទៅ ប្រាប់"** ដូចខាងក្រោម៖

**ទេ!** នៅពេលមាននរណាម្នាក់ ស្នើសុំរូបភាពផ្នែកឯកជនរបស់ខ្ញុំ ខ្ញុំត្រូវតែបដិសេធជាដាច់ខាត និងមានសិទ្ធិនិយាយថា " ទេ "

**ទៅ!** នៅពេលដែលខ្ញុំស្ថិតនៅក្នុងស្ថានភាពយាយីរំខានតាមអនឡាញដែលគួរឱ្យព្រួយបារម្ភ ភ័យខ្លាច ឬមិនសប្បាយចិត្ត នោះខ្ញុំត្រូវចាកចេញពីស្ថានភាពនោះ

**ប្រាប់!** ប្រសិនបើខ្ញុំជួបប្រទះហេតុការណ៍ណាមួយតាមអនឡាញ ដែលគួរឱ្យព្រួយបារម្ភ នោះខ្ញុំត្រូវតែប្រាប់ទៅមនុស្សដែលទុកចិត្តបំផុត



## ២. ប្រសិនបើមានការសង្ស័យពីការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទ សូមចូលរួមរាយការណ៍តាមរយៈ



- ☎ **ទូរស័ព្ទរាយការណ៍បន្ទាន់របស់នគរបាលជាតិ 1288**
- ☎ **ទូរស័ព្ទរាយការណ៍បន្ទាន់របស់អង្គការ APLE 092 311 511**
- **បណ្តាញរាយការណ៍ពិសេសរបស់អង្គការ APLE**
  **www.internethotlinecambodia.org**

# របៀបរាយការណ៍តាមរយៈបណ្តាញរាយការណ៍ពិសេសតាមប្រព័ន្ធអ៊ីនធឺណិត

## ជំហានទី១៖

ចូលទៅកាន់គេហទំព័រ www.internethotlinecambodia.org




## ជំហានទី២៖

ចុចប៊ូតុង Report Abuse ឬ រាយការណ៍ការរំលោភបំពាន




## ជំហានទី៣៖

ជ្រើសរើសយកប្រភេទករណីនៃការរំលោភបំពាន ឬ កេងប្រវ័ញ្ចផ្លូវភេទណាមួយដែលអ្នកចង់រាយការណ៍ រួចបំពេញទម្រង់ឱ្យបានត្រឹមត្រូវ




## ជំហានទី៤៖

ចុចប៊ូតុងបញ្ជូន

**សម្គាល់៖**

- អ្នកនឹងទទួលបានសារបញ្ជាក់ពីការបញ្ជូនការរាយការណ៍របស់អ្នកដោយជោគជ័យ
- អ្នកអាចធ្វើការរាយការណ៍ដោយអនាមិក

# ប្រសិនបើអ្នកសង្ស័យពីការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ

សូមរាយការណ៍តាមរយៈលេខទូរស័ព្ទ **092 311 511**

ឬតាមរយៈគេហទំព័រ **www.internethotlinecambodia.org**

លោកអ្នកក៏អាចស្កែន QR Code ដើម្បីចូលទៅកាន់គេហទំព័ររាយការណ៍ផងដែរ

ផលិតដោយ៖

APLE


023 996 351

info@aplecambodia.org

www.aplecambodia.org

/aplecambodia.org

/aple_cambodia.org

/aplecambodia



ឧបត្ថម្ភការបោះពុម្ពដោយ៖

PLAN INTERNATIONAL

Brot für die Welt